

# ច្បាប់ CARE

## ច្បាប់ ស្តីពី ជំនួយសហគមន៍ ការស្តារឡើងវិញ និងការផ្តល់សិទ្ធិអំណាច

## ឯកសារសម្រាប់ជំនួយការស្ម័គ្រចិត្ត

> សូមទាញយក សន្លឹកកិច្ចការជំនួយការស្ម័គ្រចិត្ត ដើម្បីកត់ត្រា សរសេរសំណួរផ្សេងៗ និងកំណត់ពីជំហានបន្ទាប់ដែលត្រូវអនុវត្តបន្ត។

នៅក្នុងដំណើរការនីតិវិធី CARE អ្នកឆ្លើយតបម្នាក់ៗ អាចជ្រើសរើសជំនួយការស្ម័គ្រចិត្តមួយរូប។ ជំនួយការ គឺជាមនុស្សពេញវ័យដែលធានាថាដំណើរការនីតិវិធី CARE បានឆ្លុះបញ្ចាំងពីចំណង់ចំណូលចិត្តរបស់អ្នកឆ្លើយតប។

ឯកសារនេះផ្តល់ធនធានដល់ជំនួយការស្ម័គ្រចិត្ត ដែលអាចជួយទាំងជំនួយការខ្លួនឯង និងអ្នកឆ្លើយតប ដើម្បីគ្រប់គ្រងទៅលើដំណើរការនីតិវិធី CARE។ ឯកសារនេះរួមមាន ការបណ្តុះបណ្តាល សេចក្តីសង្ខេប និងធនធានផ្សេងទៀត ដើម្បីជួយដល់ជំនួយការទៅលើតួនាទីរបស់ពួកគេ។ ធនធានទាំងអស់នេះអាចចូលប្រើប្រាស់បាននៅក្នុងបណ្ណាល័យធនធានរបស់មជ្ឈមណ្ឌលធនធានច្បាប់ CARE។

ភ្ជាប់មកជាមួយនឹងឯកសារនេះ គឺជាសន្លឹកកិច្ចការរបស់ជំនួយការស្ម័គ្រចិត្ត ដែលជំនួយការអាចទាញយកមកប្រើប្រាស់បាន។ សន្លឹកកិច្ចការនេះ មានកន្លែងទំនេរសម្រាប់កត់ត្រា សរសេរសំណួរ និងកំណត់ជំហានបន្ទាប់ដែលត្រូវអនុវត្តក្នុងដំណើរការនីតិវិធី CARE។

មាតិកា


1. **តួនាទីនៅក្នុងច្បាប់ CARE** .......... 2
2. **ទំនួលខុសត្រូវ និងគោលការណ៍ណែនាំនៃតួនាទីរបស់ជំនួយការ** .......... 4
3. **យុទ្ធសាស្ត្រសម្រាប់ជួយគាំទ្រដល់អ្នកឆ្លើយតប** .......... 5
4. **សំណួរពិភាក្សាដែលអាចចោទសួរឡើង** .......... 6
5. **ការដោះស្រាយទំនាស់ផលប្រយោជន៍** .......... 7
6. **ការចូលរួមរបស់ជំនួយការនៅក្នុងដំណើរការនីតិវិធី CARE** .......... 8
7. **ស្វ័យថៃទាំ និងភាពធន់សម្រាប់ជំនួយការស្ម័គ្រចិត្ត** .......... 12
8. **ធនធានឯកសារនានាសម្រាប់ជំនួយការ** .......... 13

# ច្បាប់ CARE៖ ឯកសារសម្រាប់ជំនួយការស្ម័គ្រចិត្ត

## 1. តួនាទីនៅក្នុងច្បាប់ CARE

មានអង្គការ និងសមាសភាពផ្សេងៗគ្នាជាច្រើនដើម្បីជួយបុគ្គលម្នាក់ៗក្នុងអំឡុងពេលដំណើរការនីតិវិធី CARE។ តួនាទីចម្បងៗត្រូវបានរៀបរាប់ខាងក្រោម។ ក្នុងនាមជាជំនួយការ វាអាចមានប្រយោជន៍ក្នុងការចងក្រងព័ត៌មាននេះទុកនៅក្នុងសន្លឹកកិច្ចការជំនួយការស្ម័គ្រចិត្ត។

| តួនាទី | ការពិពណ៌នា |
|---|---|
| **អ្នកឆ្លើយតប / អ្នកចូលរួម ក្នុងច្បាប់ CARE** | នៅពេលដែលញត្តិត្រូវបានដាក់ជូន បុគ្គលដែលត្រូវបានគេវាយតម្លៃសម្រាប់ការចូលរួមក្នុងដំណើរការនីតិវិធី CARE ត្រូវបានគេហៅថាជា *អ្នកឆ្លើយតប*។ ពាក្យនេះច្រើនតែប្រើសម្រាប់រូបវន្តបុគ្គលដែលឆ្លងកាត់ដំណើរការនីតិវិធីតុលាការ។ ជាទូទៅ យើងសំដៅទៅលើបុគ្គលណាម្នាក់ដែលចូលរួមក្នុងច្បាប់ CARE ថាជា*អ្នកចូលរួមក្នុងច្បាប់ CARE* ប៉ុន្តែអ្នកអាចឃើញ ឬស្តាប់ឮ ពាក្យ *អ្នកឆ្លើយតប*នេះ នឹងត្រូវបានប្រើប្រាស់ផងដែរ។<br><br>ក្នុងដំណើរការនីតិវិធីនេះ បុគ្គលនេះ នឹងមានសិទ្ធិចូលប្រើប្រាស់សេវាសុខផ្នែកភាពអាកប្បកិរិយា លំនៅឋាន និងការគាំជួយទ្រសហគមន៍ផ្សេងទៀត តាមការចាំបាច់។ |
| **ជំនួយការស្ម័គ្រចិត្ត** | ជាមនុស្សពេញវ័យដែលត្រូវបានជ្រើសរើសដោយអ្នកឆ្លើយតបដើម្បីផ្តល់ការជួយគាំទ្រពេញមួយដំណើរការនីតិវិធី CARE និងដើម្បីលើកកម្ពស់ចំណង់ចំណូលចិត្ត ជម្រើស និងស្វ័យភាពរបស់អ្នកឆ្លើយតប។ |
| **អ្នកដាក់ញត្តិ** | ជាបុគ្គលដែលបានដាក់ញត្តិឱ្យអ្នកឆ្លើយតបដើម្បីឱ្យមានការពិចារណាសម្រាប់ដំណើរការនីតិវិធី CARE។ ឧទាហរណ៍ អ្នកដាក់ញត្តិរួមមាន សមាជិកគ្រួសារ អ្នកជំនាញសុខភាពផ្លូវចិត្ត អ្នកឆ្លើយតបដំបូង អ្នកធ្វើការផ្សព្វផ្សាយដែលគ្មានផ្ទះសម្បែង ឬមិត្តរួមបន្ទប់/មិត្តរួមគេហដ្ឋាន។ សម្រាប់ធនធានបន្ថែមអំពីញត្តិ (ព្រមទាំងបញ្ជីលម្អិតនៃបុគ្គលដែលអាចជាអ្នកដាក់ញត្តិ) សូមមើល <u>ធនធានច្បាប់ CARE សម្រាប់អ្នកដាក់ញត្តិ</u>។ |
| **ភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធី** | ភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធី និងក្រុមការងាររបស់ពួកគេមានតួនាទីយ៉ាងសំខាន់ក្នុងដំណើរការនីតិវិធីតុលាការ។ ភ្នាក់ងារដែលចូលរួមជាមួយអ្នកឆ្លើយតបក្នុងការព្យាបាលសុខភាពផ្លូវចិត្ត |

### ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែមអំពីតួនាទីរបស់ច្បាប់ CARE សូមមើលវគ្គបណ្តុះបណ្តាលស្តីពី **<u>ទិដ្ឋភាពទូទៅនៃដំណើរការនីតិវិធី CARE សម្រាប់ជំនួយការ</u>**។

សម្រាប់ព័ត៌មានបន្ថែមអំពីតួនាទីនៅក្នុងតុលាការ CARE សូមមើល**<u>តួនាទីផ្លូវច្បាប់នៅក្នុងសេចក្តីសង្ខេបនៃច្បាប់ CARE</u>**។

សម្រាប់ព័ត៌មានបន្ថែមអំពីតម្រូវការសិទ្ធិទទួលបានដើម្បីចូលរួមក្នុងដំណើរការនីតិវិធី CARE សូមមើល **<u>ឯកសារព័ត៌មាននៃលក្ខខណ្ឌសិទ្ធិទទួលបានច្បាប់ CARE</u>**។

| | |
|---|---|
| | និងភ្ជាប់ពួកគេទៅកាន់សេវាកម្មបន្ថែម។ បុគ្គលម្នាក់ៗ អាចដាក់បញ្ចូលអ្នកផ្តល់សេវាកម្មកិច្ចសន្យា អ្នកចេញវេជ្ជបញ្ជា និង/ឬអ្នកគ្រប់គ្រងថៃទាំ។ |
| **អ្នកផ្តល់សេវាកម្ម ផ្នែកលំនៅឋាន និងការជួយគាំទ្រសហគមន៍** | អ្នកឆ្លើយតបអាចភ្ជាប់ទំនាក់ទំនងជាមួយនឹងអ្នកផ្តល់សេវាកម្ម ផ្នែកលំនៅឋាន និងការជួយគាំទ្រសហគមន៍តាមរយៈដំណើរការនីតិវិធី CARE។<br><br>ឧទាហរណ៍នៃអ្នកផ្តល់សេវាកម្ម លំនៅឋាន រួមមាន លំនៅឋានគាំទ្រអចិន្ត្រៃយ៍ លំនៅឋានដែលមានតម្លៃសមរម្យ លំនៅឋានបណ្តោះអាសន្ន/អន្តរកាល និងលំនៅឋានអន្តរកាលសម្រាប់ការព្យាបាលសុខភាពផ្នែកអាកប្បកិរិយា (BHBH)។<br><br>ឧទាហរណ៍ ពីការជួយគាំទ្រសហគមន៍ដែលអ្នកផ្តល់សេវាកម្មអាចផ្តល់ជូនរួមមាន សេវាសង្គមដែលផ្តល់មូលនិធិតាមរយៈប្រាក់ចំណូលសន្តិសុខបន្ថែម/ការទូទាត់បន្ថែមរបស់រដ្ឋ (SSI/SSP) ជំនួយហិរញ្ញវត្ថុសម្រាប់ជនអន្តោប្រវេសន៍ កម្មវិធី CalWORKs កម្មវិធីជំនួយស្បៀងអាហាររដ្ឋកាលីហ្វ័រញ៉ា កម្មវិធីសេវាជំនួយតាមផ្ទះ និង កម្មវិធី CalFresh។ |
| **តុលាការ CARE** | បុគ្គលដែលធ្វើការឱ្យប្រព័ន្ធតុលាការដែលនឹងចូលរួមក្នុងដំណើរការនីតិវិធី CARE រួមមាន៖<br><br>• ទីប្រឹក្សាសម្រាប់សុខភាពអាកប្បកិរិយា<br>    • ពួកគេទទួលខុសត្រូវធ្វើជាតំណាងឱ្យភ្នាក់ងារសុខភាពអាកប្បកិរិយារបស់ខោនធី។ បុគ្គលទាំងអស់នេះអាចជាទីប្រឹក្សារបស់ខោនធី ឬមេធាវីដែលបានចាត់តាំងផ្សេងទៀត។<br><br>• ជំនួយផ្នែកច្បាប់/មេធាវីរដ្ឋ<br>    • ពួកគេទទួលខុសត្រូវធ្វើជាតំណាងឱ្យផលប្រយោជន៍ និងសិទ្ធិរបស់អ្នកឆ្លើយតប។ ពួកគេត្រូវបានតែងតាំង និងផ្តល់ឱ្យ ដោយតុលាការ ដោយមិនគិតពីលទ្ធភាពបង់ប្រាក់របស់អ្នកឆ្លើយតបឡើយ។<br><br>• ចៅក្រម<br>    • ចៅក្រមបំពេញការងារ ជាអាជ្ញាកណ្តាលអព្យាក្រឹត។ ក្នុងករណីដែលគ្មានវិវាទកើតឡើងទេ ពួកគេនឹងគ្រប់គ្រងសំណុំរឿងនេះក្នុងលក្ខណៈក្រៅផ្លូវការ និងប្រកបដោយភាពរួសរាយរាក់ទាក់។ |

## 2. ទំនួលខុសត្រូវ និងគោលការណ៍ណែនាំនៃតួនាទីរបស់ជំនួយការ

ច្បាប់ CARE ពិពណ៌នាអំពីទំនួលខុសត្រូវរបស់ជំនួយការ និងគោលការណ៍សំខាន់ៗពីតួនាទីនេះ។ តួនាទីរបស់ជំនួយការនៅក្នុងសេចក្តីសង្ខេបនៃច្បាប់ CARE ផ្តល់ព័ត៌មានជាជំនួយអំពីទំនួលខុសត្រូវ និងគោលការណ៍ទាំងអស់នេះ។

ការអនុវត្តន៍ជាក់ស្តែងនៃទំនួលខុសត្រូវ និងគោលការណ៍ទាំងអស់នេះគឺអាស្រ័យទៅលើតម្រូវការ និងចំណង់ចំណូលចិត្តរបស់អ្នកឆ្លើយតប។ អ្នកអាចប្រើប្រាស់សន្លឹកកិច្ចការជំនួយការស្ម័គ្រចិត្តដើម្បីចងក្រងជាឯកសារដែលអាចជួយដល់ការយល់ដឹងរបស់អ្នកអំពីទំនួលខុសត្រូវ និងចំណង់ចំណូលចិត្តទាំងអស់នេះ និងដើម្បីកត់ត្រាសំណួរបន្ថែមដែលអ្នកចង់សួរផងដែរ។

| | |
|---|---|
| **ទំនួលខុសត្រូវរបស់ជំនួយការស្ម័គ្រចិត្ត** | • ជួយអ្នកឆ្លើយតបឱ្យយល់ ប្រតិបត្តិ និងទំនាក់ទំនងទៅលើការសម្រេចចិត្ត និងបង្ហាញពីចំណង់ចំណូលចិត្តពេញមួយដំណើរការនីតិវិធី CARE។<br>• ផ្តល់ជូនអ្នកឆ្លើយតបនូវមធ្យោបាយនានាដែលមានលក្ខណៈបត់បែន និងស្របតាមវប្បធម៌ ដើម្បីរក្សាសិទ្ធិអំណាចក្នុងការសម្រេចចិត្តទៅលើជីវិតរបស់ពួកគេក្នុងកម្រិតមួយដែលអាចធ្វើទៅបាន តាមរយៈការអភិវឌ្ឍន៍ និងការថែរក្សាប្រព័ន្ធជួយគាំទ្រដោយស្ម័គ្រចិត្ត។<br>• ប្រើវិធីសាស្ត្រការសម្រេចដោយមានការជួយគាំទ្រ (SDM) ដើម្បីបង្កើនសមត្ថភាពរបស់អ្នកឆ្លើយតបក្នុងការធ្វើការសម្រេចចិត្តដោយខ្លួនរបស់ពួកគេផ្ទាល់។ |
| **គោលការណ៍របស់ជំនួយការស្ម័គ្រចិត្ត** | • ការសម្រេចចិត្តដោយមានការជួយគាំទ្រ។<br>• ជៀសវាងមានការលំអៀងផ្ទាល់ខ្លួន។<br>• ការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេស។<br>• ការសម្ងាត់។ |

### *ព័ត៌មានបន្ថែម*

សម្រាប់ព័ត៌មានបន្ថែមអំពីតួនាទីរបស់ជំនួយការស្ម័គ្រចិត្ត សូមមើលតួនាទីរបស់ជំនួយការនៅក្នុងសេចក្តីសង្ខេបច្បាប់ CARE។

សម្រាប់ព័ត៌មានបន្ថែម សូមមើលវគ្គបណ្តុះបណ្តាលស្តីពីការសម្រេចដោយមានការជួយគាំទ្រសម្រាប់ជំនួយការស្ម័គ្រចិត្ត និងការរក្សាអព្យាក្រឹតភាពក្នុងនាមជាជំនួយការស្ម័គ្រចិត្ត។

សូមមើលឯកសារបណ្តុះបណ្តាល ស្តីពី ការថែការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេស (TIC) រួមទាំងមូលនិធិសម្រាប់ TIC គោលដៅ និងគោលការណ៍របស់ TIC និងការអនុវត្តន៍ TIC ក្នុងការអនុវត្តផ្ទាល់។

## 3. យុទ្ធសាស្ត្រសម្រាប់ជួយគាំទ្រដល់អ្នកឆ្លើយតប

អ្នកឆ្លើយតបម្នាក់ៗមានតម្រូវការ និងចំណង់ចំណូលចិត្តខុសៗគ្នា។ ជំនួយការគួរតែប្រើយុទ្ធសាស្ត្រថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេសដើម្បីជួយអ្នកឆ្លើយតបបង្កើតភាពធន់នៅក្នុងដំណើរការនីតិវិធី CARE។

ការបណ្តុះបណ្តាល ស្តីពី ការអនុវត្តការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេសក្នុងការអនុវត្តផ្ទាល់ ផ្តល់នូវយុទ្ធសាស្ត្រមួយចំនួនដើម្បីជួយគាំទ្រដល់អ្នកឆ្លើយតប។ វគ្គបណ្តុះបណ្តាលនេះ ពិភាក្សាអំពីវិធីសាស្ត្រដើម្បី៖

1. រៀបចំផែនការទុកជាមុនសម្រាប់ស្ថានភាពដែលមានភាពតានតឹង។
2. ជួយអ្នកឆ្លើយតបឱ្យអនុវត្តវិធីសាស្ត្រអត់ធ្មត់។
3. ដោះស្រាយស្ថានការណ៍ដោយចិត្តមេត្តា និងការដាក់ខ្លួន។
4. ដោះស្រាយភាពលំអៀងដែលរារាំងដល់ការផ្តល់ការជួយគាំទ្រ។
5. សង្កត់ធ្ងន់លើចំណុចខ្លាំងរបស់អ្នកឆ្លើយតប។
6. ស្តាប់ដោយយកចិត្តទុកដាក់។

ចាំបាច់ណាស់ដែលត្រូវរក្សាអព្យាក្រឹតភាពក្នុងតួនាទីជាជំនួយការ។ ការប្តូរពីតួនាទីជាមិត្តភក្តិ ឬជាសមាជិកគ្រួសារទៅជាតួនាទី "ជំនួយការ" វិញអាចជាការផ្លាស់ប្តូរដ៏លំបាកមួយ។ ជំនួយការអាចប្រើបច្ចេកទេសមួយចំនួនដើម្បីរក្សាភាពអព្យាក្រឹតរបស់ខ្លួន នៅពេលដែលអ្នកឆ្លើយតបកំពុងពិចារណាលើការសម្រេចចិត្ត ដូចជាការប្រើជំនាញស្តាប់ដោយមានការឆ្លុះបញ្ចាំង និងការបែងចែកឱ្យដាច់រវាងទំនាក់ទំនងជាប្រវត្តិសាស្ត្រ និងតួនាទីជាជំនួយការស្ម័គ្រចិត្ត។ ជំនួយការ និងអ្នកឆ្លើយតបគួរតែប្រើក្របខ័ណ្ឌនៃការសម្រេចចិត្តដោយមានការជួយគាំទ្រ ដើម្បីធានាថាអ្នកឆ្លើយតបទទួលបានការជួយគាំទ្រ និងសេវាកម្មដែលត្រូវការ ដើម្បីធ្វើការសម្រេចចិត្តបានដោយឯករាជ្យ។

### ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែម សូមមើល វគ្គបណ្តុះបណ្តាល ស្តីពី ការអនុវត្តការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេសក្នុងការអនុវត្តផ្ទាល់ ការសម្រេចចិត្តដោយមានការជួយគាំទ្រសម្រាប់ជំនួយការស្ម័គ្រចិត្ត និងការរក្សាអព្យាក្រឹតភាពក្នុងនាមជាជំនួយការស្ម័គ្រចិត្ត។

## 4. សំណួរពិភាក្សាដែលអាចចោទសួរឡើង

សន្លឹកកិច្ចការរបស់ជំនួយការស្ម័គ្រចិត្តមានសំណួរគំរូជាច្រើន ដែលជំនួយការអាចប្រើប្រាស់ដើម្បីឱ្យយល់កាន់តែច្បាស់ពីតម្រូវការ ចំណង់ចំណូលចិត្ត និងគោលដៅរបស់អ្នកឆ្លើយតប។ ជំនួយការ និងអ្នកឆ្លើយតបគួរតែពិចារណាក្នុងការកំណត់ពេលវេលាដើម្បីពិភាក្សាគ្នាទៅលើសំណួរទាំងអស់នេះទាក់ទងនឹងចំណង់ចំណូលចិត្តទាំងអស់នេះ និងចំណង់ចំណូលចិត្តបន្ថែមទៀត។

- តើអ្វីជាគោលដៅរបស់អ្នកចំពោះការចូលរួមក្នុងដំណើរការនីតិវិធី CARE នេះ? (ឧ. ដើម្បីទទួលបានសេវាកម្ម ដើម្បីបញ្ចប់ពីគម្រោង។ល។)
- តើអ្វីទៅជាគោលដៅរួមរបស់អ្នក?
- សូមប្រាប់ខ្ញុំពីការយល់ដឹងរបស់អ្នក និងសំណួរនានាអំពីមូលហេតុដែលអ្នកចូលរួមក្នុងដំណើរការនីតិវិធី CARE។
- សូមប្រាប់ខ្ញុំពីការយល់ដឹងរបស់អ្នក និងសំណួរនានាអំពីគោលបំណងនៃដំណើរការនីតិវិធីតុលាការ CARE។
- សូមប្រាប់ខ្ញុំពីការយល់ដឹងរបស់អ្នក និងសំណួរនានាអំពីការទទួលខុសត្រូវរបស់អ្នកនៅក្នុងដំណើរការនីតិវិធី CARE។
- តើអ្នកយល់ពីតួនាទីរបស់ខ្ញុំក្នុងការជួយអ្នកក្នុងដំណើរការនីតិវិធី CARE ទេ?
- ចុះដំណើរការច្បាប់ CARE វិញ តើវាធ្វើឱ្យអ្នកមានការភ័យខ្លាច ឬមានភាពតានតឹងខ្លាំងទេ?
- តើអ្នកមានអារម្មណ៍យ៉ាងណាដែរ នៅពេលអ្នកនៅក្បែរអាជ្ញាធរមានសមត្ថកិច្ច? តើយុទ្ធសាស្ត្រ ឬសកម្មភាពអ្វីខ្លះដែលអ្នកយល់ឃើញថាមានប្រយោជន៍ចំពោះអ្នកក្នុងស្ថានភាពទាំងអស់នោះ?
- តើចំណុចសំខាន់ ឬកត្តាអ្វីខ្លះដែលអ្នកចង់ឱ្យខ្ញុំចងចាំ?
- តើអ្នកឆ្លើយតបយ៉ាងដូចម្ដេចចំពោះបរិយាកាសផ្លូវការ ដូចជាក្នុងបន្ទប់តុលាការ? តើយុទ្ធសាស្ត្រ ឬសកម្មភាពអ្វីខ្លះដែលអ្នកយល់ឃើញថាមានប្រយោជន៍ចំពោះអ្នកក្នុងស្ថានភាពទាំងអស់នោះ?
- តើធ្វើយ៉ាងដូចម្តេចដើម្បីឱ្យខ្លួនឯងមានភាពអត់ធ្មត់នៅពេលដែលអ្នកមានការភ័យខ្លាច ឬភាពតានតឹង? តើមានព័ត៌មានផ្សេងទៀតដែលមានប្រយោជន៍ទេ?
- តើអ្នកត្រូវការជំនួយអ្វីខ្លះដើម្បីជួយអ្នកក្នុងការធ្វើការសម្រេចចិត្ត?
- តើខ្ញុំអាចធ្វើអ្វីបានខ្លះដើម្បីជួយអ្នកក្នុងដំណើរការនីតិវិធី CARE?
- តើអ្នកមានឯកសារណែនាំបម្រុងសម្រាប់ការព្យាបាលជំងឺផ្លូវចិត្ត (PAD) ដែរឬទេ?
    - ប្រសិនបើបាទ/ចាស តើអ្នកចង់ឱ្យខ្ញុំចូលប្រើប្រាស់វាដែរឬទេ? តើអ្នកផ្សេងទៀតមានសិទ្ធិចូលប្រើប្រាស់វាទេ?
    - បើអត់មានទេ តើអ្នកចាប់អារម្មណ៍ចង់បង្កើតវាទេ?

## 5. ការដោះស្រាយទំនាស់ផលប្រយោជន៍

តុលាការអាចនឹងដកជំនួយការចេញ ប្រសិនបើមានទំនាស់ផលប្រយោជន៍ដែលមិនអាចដោះស្រាយបាន។ ឧទាហរណ៍ ជម្លោះអាចនឹងកើតមានឡើង នៅពេលដែលជំនួយការមិនអាចរក្សាភាពអព្យាក្រឹតបាន ដោយសារពួកគេមិនយល់ស្របជាមួយនឹងចំណង់ចំណូលចិត្ត ឬការសម្រេចចិត្តរបស់អ្នកឆ្លើយតប។ លើសពីនេះទៀត ជម្លោះអាចនឹងកើតមានឡើង ប្រសិនបើជំនួយការអាចទទួលបានអត្ថប្រយោជន៍ផ្ទាល់ខ្លួន ឬផ្នែកហិរញ្ញវត្ថុពីការសម្រេចចិត្តរបស់អ្នកឆ្លើយតប។ ប្រសិនបើខ្លួនអ្នកដែលជាជំនួយការមានអារម្មណ៍ថា ខ្លួនមិនអាចជួយគាំទ្រអ្នកឆ្លើយតបក្នុងនាមជាភាគីអព្យាក្រឹតបានទេ សូមប្រាប់អ្នកឆ្លើយតប និង/ឬមេធាវីរបស់អ្នកឆ្លើយតបឱ្យបានដឹងផង។

## 6. ការចូលរួមរបស់ជំនួយការនៅក្នុងដំណើរការនីតិវិធី CARE

នៅផ្នែកនេះផ្តល់នូវទិដ្ឋភាពទូទៅលម្អិតពីដំណើរការនីតិវិធី CARE ដោយផ្តោតលើតួនាទីសំខាន់ៗដែលអាចកើតមានឡើងរបស់ជំនួយការ។ ព័ត៌មាននៅក្នុងផ្នែកនេះ រួមជាមួយនឹងការណែនាំផ្សេងទៀតដែលមាននៅក្នុងឯកសារនេះ ធ្វើការសង្ខេបព័ត៌មានពីលក្ខន្តិកៈច្បាប់ CARE។

ដោយសារដំណើរការនីតិវិធីរបស់តុលាការមានភាពស្មុគស្មាញ វាអាចធ្វើឱ្យជំនួយការមានអារម្មណ៍ច្របូកច្របល់។ សូមចំណាំថា ជំនួយការមិនទទួលខុសត្រូវចំពោះការតាមដានកាលបរិច្ឆេទសវនាការ ឬឯកសារសេចក្តីសម្រេចរបស់តុលាការឡើយ ប៉ុន្តែ អ្នកឆ្លើយតបនឹងដឹងគុណអ្នកប្រសិនបើជាអ្នកអាចជួយស្វែងយល់អំពីដំណើរការនីតិវិធី និងជំហានបន្ទាប់ដែលត្រូវអនុវត្ត។ ប្រសិនបើជំនួយការមិនមែនជាអ្នកដាក់ញត្តិដំបូងទេ នោះការចូលរួមក្នុងដំណើរការនីតិវិធីជាលើកដំបូងរបស់ពួកគេ ប្រហែលជាមិនមានទេ រហូតដល់ថ្ងៃបង្ហាញខ្លួនដំបូងនៅសវនាការទើបពួកគេអាចចូលរួមបាន។

តួនាទីដែលជំនួយការអនុវត្តអាចនឹងមានភាពខុសប្លែកគ្នា អាស្រ័យទៅលើតម្រូវការ និងចំណង់ចំណូលចិត្តរបស់អ្នកឆ្លើយតបម្នាក់ៗ។ ជំនួយការគួរតែរៀបចំផែនការជាមួយនឹងអ្នកឆ្លើយតបពីរបៀបដែលពួកគេចង់ឱ្យជំនួយការចូលរួម។ ផែនការនេះគួរតែត្រូវបានពិនិត្យមើលឡើងវិញជាមួយនឹងអ្នកឆ្លើយតបក្នុងពេលដំណើរការនីតិវិធី CARE។

ជំនួយការគួរតែចងក្រងឯកសារផែនការរបស់ពួកគេសម្រាប់ការចូលរួមនៅក្នុងសន្លឹកកិច្ចការជំនួយការស្ម័គ្រចិត្ត។

### ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែមអំពីលំហូរនៃតុលាការ CARE សូមមើល **សេចក្តីសង្ខេបនៃលំហូរដំណើរការនីតិវិធី CARE ឆ្ពោះទៅរកការព្យាបាល លំនៅឋាន និងការជួយគាំទ្រ** និង**ទិដ្ឋភាពទូទៅនៃដំណើរការនីតិវិធី CARE សម្រាប់ការបណ្តុះបណ្តាល**ជំនួយការ។

| ជំហាននៅក្នុងដំណើរការនីតិវិធី | ការពិពណ៌នា អំពីជំហាន |
|---|---|
| **ដំណើរការនីតិវិធី CARE បឋម** | |
| ការដាក់ញត្តិដំបូង | ញត្តិដំបូងត្រូវបានដាក់ទៅតុលាការដើម្បីផ្តួចផ្តើមដំណើរការនីតិវិធី CARE ឡើង។ ញត្តិនេះត្រូវតែផ្តល់ព័ត៌មានជាក់លាក់ និងព័ត៌មានគាំទ្រឱ្យបានច្បាស់ដល់តុលាការដើម្បីធ្វើការពិចារណាក្នុងការសម្រេចថាតើអ្នកឆ្លើយតបមានសិទ្ធិទទួលបានសម្រាប់ដំណើរការនីតិវិធីដែរឬអត់។ |
| **ការចូលរួម** | |

# ច្បាប់ CARE៖ ឯកសារសម្រាប់ជំនួយការស្ម័គ្រចិត្ត

| ជំហាននៅក្នុងដំណើរការនីតិវិធី | ការពិពណ៌នា អំពីជំហាន |
| --- | --- |
| ការសម្រេចទៅលើភស្តុតាងបឋម (ឧ. ចំណាប់អារម្មណ៍ដំបូង) | តុលាការនឹងធ្វើការសម្រេចថាតើញត្តិបង្ហាញថាអ្នកឆ្លើយតបអាចមានសិទ្ធិទទួលបានសម្រាប់ដំណើរការនីតិវិធី CARE ដែរឬអត់។ |
| របាយការណ៍ខោនធី | ប្រសិនបើញត្តិត្រូវបានដាក់ដោយអ្នកផ្សេងក្រៅពីភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធី តុលាការនឹងចេញដីកាបង្គាប់ឱ្យភ្នាក់ងារធ្វើការស៊ើបអង្កេត និងរាយការណ៍ថាតើអ្នកឆ្លើយតបបានបំពេញតាមលក្ខណៈវិនិច្ឆ័យ CARE ដែរឬអត់។ ភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធីនឹងព្យាយាមឱ្យអ្នកឆ្លើយតបចូលរួមក្នុងសេវាកម្មស្ម័គ្រចិត្ត ហើយរាយការណ៍ពីលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងនេះទៅឱ្យតុលាការ។ |
| **ដំណើរការនីតិវិធីតុលាការ/ការតភ្ជាប់សេវាកម្ម** | |
| ការបង្ហាញខ្លួននៅក្នុងអង្គសវនាការដំបូង | នេះជាលើកទីមួយដែលភាគីទាំងអស់បង្ហាញខ្លួននៅតុលាការ។ ទីប្រឹក្សា (មេធាវី) របស់អ្នកឆ្លើយតបនឹងត្រូវបានតែងតាំងឡើងនៅមុនការបង្ហាញខ្លួននៅតុលាការ។ ក្នុងអំឡុងពេលនៃការបង្ហាញខ្លួននៅតុលាការនេះ (និងនៅពេលដំណើរការនីតិវិធី) អ្នកឆ្លើយតបមានជម្រើសក្នុងការជ្រើសរើសជំនួយការខ្លួន។ អ្នកឆ្លើយតបអាចសម្រេចចិត្តទៅចូលរួមក្នុងសវនាការរបស់តុលាការនេះដោយខ្លួនឯង ឬពួកគេអាចឱ្យមេធាវីរបស់ពួកគេទៅបង្ហាញខ្លួននៅតុលាការជំនួសពួកគេបាន។ ភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធីនឹងជំនួសអ្នកដាក់ញត្តិប្រសិនបើញត្តិត្រូវបានដាក់ដោយអ្នកផ្សេង។ |
| អង្គសវនាការលើអង្គហេតុ និងភស្តុតាង | តុលាការនឹងសម្រេចថាតើអ្នកឆ្លើយតបបានបំពេញតាមលក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន CARE ដែរឬអត់។ បើដូច្នេះមែន តុលាការនឹងចេញដីកាបង្គាប់ឱ្យភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធី ធ្វើការជាមួយអ្នកឆ្លើយតប (ទីប្រឹក្សា និងជំនួយការរបស់ពួកគេ) ដើម្បីឱ្យចូលរួមក្នុងការព្យាបាល និងព្យាយាមបង្កើតកិច្ចព្រមព្រៀង CAREឡើង។ សវនាការនេះអាចត្រូវបានបញ្ចូលគ្នាជាមួយនឹងការបង្ហាញខ្លួននៅតុលាការដំបូង។ |
| ការអភិវឌ្ឍន៍កិច្ចព្រមព្រៀង CARE | កិច្ចព្រមព្រៀង CARE គឺជាកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្តដែលបង្កើតឡើងដោយអ្នកឆ្លើយតប មេធាវី ជំនួយការរបស់ពួកគេ និងភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធី (ភាគី)។ កិច្ចព្រមព្រៀង CARE កំណត់នូវសេវាកម្ម និងការជួយគាំទ្រជាច្រើនដែលនឹងផ្តល់អត្ថប្រយោជន៍ដល់អ្នកឆ្លើយតប។ |
| សវនាការលើការគ្រប់គ្រងសំណុំរឿង | ប្រសិនបើកិច្ចព្រមព្រៀង CARE ត្រូវបានសម្រេចយក តុលាការនឹងពិនិត្យមើល និងអាចអនុម័តលើកិច្ចព្រមព្រៀងនេះ។ បន្ទាប់មក តុលាការនឹងកំណត់ពេលសវនាការពិនិត្យមើលវឌ្ឍនភាពមួយ ដើម្បីតាមដានទៅលើការអនុលោមតាមកិច្ច |

| ជំហាននៅក្នុងដំណើរការនីតិវិធី | ការពិពណ៌នា អំពីជំហាន |
| --- | --- |
| | ព្រមព្រៀងរបស់អ្នកឆ្លើយតប។ ប្រសិនបើកិច្ចព្រមព្រៀង CARE មិនអាចសម្រេចបានទេ តុលាការនឹងចេញដីកាបង្គាប់ឱ្យភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធី ធ្វើការវាយតម្លៃការព្យាបាលលើអ្នកឆ្លើយតប។ |
| ការវាយតម្លៃការព្យាបាល | ភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធីនឹងរាយការណ៍ទៅតុលាការលើ៖<br>• ការធ្វើរោគវិនិច្ឆ័យការព្យាបាលរបស់អ្នកឆ្លើយតប។<br>• ថាតើអ្នកឆ្លើយតបមានសមត្ថភាពផ្លូវច្បាប់ក្នុងការផ្តល់ការយល់ព្រមដោយមានព័ត៌មានគ្រប់ជ្រុងជ្រោយទាក់ទងនឹងការផ្តល់ឱសថជំងឺផ្លូវចិត្តដែរឬអត់។<br>• ព័ត៌មានបន្ថែម និងអនុសាសន៍នានាសម្រាប់សេវាកម្ម និងការជួយគាំទ្រដែលអាចជួយដល់តុលាការក្នុងការធ្វើការសម្រេចចិត្ត។ |
| សវនាការលើការវាយតម្លៃការព្យាព្យាបាល | តុលាការពិនិត្យមើលការវាយតម្លៃការព្យាបាល និងភស្តុតាងផ្សេងទៀតដែលបានបង្ហាញ។ តុលាការនឹងសម្រេចថាតើអ្នកឆ្លើយតបបានបំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានសិទ្ធិទទួលបានឬអត់ និងចេញដីកាបង្គាប់ឱ្យបង្កើតគម្រោង CARE។ |
| ការអភិវឌ្ឍន៍គម្រោង CARE | ដូចជាកិច្ចព្រមព្រៀង CARE ដែរ គម្រោង CARE នឹងកំណត់លើសេវាកម្ម និងការជួយគាំទ្រជាច្រើនដល់អ្នកឆ្លើយតប។ អ្នកឆ្លើយតប មេធាវីរបស់ពួកគេ ភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធី និងជំនួយការនឹងធ្វើការរួមគ្នាដើម្បីបង្កើតគម្រោង CARE ឡើង។ ប្រសិនបើពួកគេមិនយល់ព្រមលើគម្រោងនោះទេ ភ្នាក់ងារសុខភាពផ្នែកអាកប្បកិរិយារបស់ខោនធី និងអ្នកឆ្លើយតបអាចស្នើបង្កើតគម្រោងផែនការដាច់ដោយឡែកមួយទៀត។ |
| អង្គសវនាការពិនិត្យលើគម្រោង CARE | តុលាការទទួលយកធាតុផ្សំនៃគម្រោង CARE ដែលបានស្នើឡើង ដែលជួយគាំទ្រល្អបំផុតដល់ការស្តារឡើងវិញ និងស្ថេរភាពរបស់អ្នកឆ្លើយតប ហើយអាចចេញដីកាបង្គាប់ចាំបាច់ដល់អ្នកឆ្លើយតបដើម្បីចូលប្រើប្រាស់សេវាកម្មទាំងអស់នោះ។ |
| **ការផ្តល់សេវាកម្ម** | |
| សវនាការពិនិត្យមើលស្ថានភាព (នៅរៀងរាល់ 60 ថ្ងៃ ម្តង) | សវនាការពិនិត្យមើលស្ថានភាពផ្តល់ឱ្យតុលាការនូវឱកាសមួយដើម្បីតាមដានលើវឌ្ឍនភាពរបស់អ្នកឆ្លើយតបក្នុងការបំពេញគម្រោង CARE របស់ពួកគេ ហើយនឹងធ្វើការពិចារណាថាតើគួរមានការផ្លាស់ប្តូរណាមួយដែលចាំបាច់ដែលត្រូវធ្វើឬអត់។ |

| ជំហាននៅក្នុងដំណើរការនីតិវិធី | ការពិពណ៌នា អំពីជំហាន |
|---|---|
| | តុលាការក៏នឹងធ្វើការសម្រេចថាតើអ្នកឆ្លើយតបអាចចូលប្រើប្រាស់សេវាកម្មទាំងនោះបាន និងបានដោះស្រាយបញ្ហានានាដែលអាចនឹងកើតឡើងដែរឬអត់។ |
| **ជំហានបន្ទាប់** | |
| **សវនាការពិនិត្យស្ថានភាពរយៈពេលមួយឆ្នាំ (ធ្វើនៅខែ ទី 11)** | នៅក្នុងសវនាការនេះ តុលាការនឹងសម្រេចថាតើអ្នកឆ្លើយតបនឹងត្រូវបញ្ចប់ពីដំណើរការនីតិវិធី CARE ដែរឬអត់។ ប្រសិនបើអ្នកឆ្លើយតបត្រូវជ្រើសរើសឱ្យបញ្ចប់ពីគម្រោង ហើយតុលាការយល់ព្រមដែរ តុលាការនឹងចេញដីកាបង្គាប់ឱ្យភាគីទាំងអស់រៀបចំផែនការបញ្ចប់គម្រោង។ |
| **សវនាការបញ្ចប់គម្រោង** | ផែនការបញ្ចប់គម្រោងនឹងត្រូវបានបង្ហាញដល់តុលាការដើម្បីពិនិត្យមើល។ ផែនការបញ្ចប់គម្រោងគឺជាកិច្ចព្រមព្រៀងស្ម័គ្រចិត្តដែលដាក់បញ្ចូលនូវយុទ្ធសាស្ត្រដើម្បីជួយគាំទ្រដល់ការធ្វើបរិវត្តកម្មដោយជោគជ័យរបស់អ្នកឆ្លើយតបចាកចេញពីដំណើរការនីតិវិធី CARE។ |
| **ការបន្តគម្រោងឡើងវិញ** | ដោយមានការអនុញ្ញាតពីតុលាការ អ្នកឆ្លើយតបអាចជ្រើសរើសបន្តនៅក្នុងដំណើរការនីតិវិធី CARE រហូតដល់ទៅមួយឆ្នាំបន្ថែមទៀត។ ក្នុងករណីខ្លះ តុលាការអាចបន្តគម្រោងឱ្យអ្នកឆ្លើយតបក្នុងដំណើរការនីតិវិធីនេះរហូតដល់មួយឆ្នាំទៀតដោយគ្មានការយល់ព្រមពីពួកគេ។ |

## 7. ស្វ័យថែទាំ និងភាពធន់សម្រាប់ជំនួយការស្ម័គ្រចិត្ត

ការបម្រើការងារជាជំនួយការក្នុងដំណើរការនីតិវិធី CARE គឺជាតួនាទីដ៏សំខាន់ និងប្រឈមបំផុត ហើយជំនួយការខ្លួនឯងអាចជួបប្រទះភាពតានតឹង និងការប៉ះទង្គិចផ្លូវចិត្ត។ ការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេសអាចជួយឱ្យជំនួយការអាចបណ្ដុះស្វ័យថែទាំ និងភាពធន់បាន។ យុទ្ធសាស្រ្តថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេសរួមមាន ការផ្តល់អាទិភាពដល់ស្វ័យថែទាំ ការការពារការអស់កម្លាំង ការគ្រប់គ្រងភាពតានតឹង ការបង្កើតព្រំដែនច្បាស់លាស់ និងការស្វែងរកជំនួយនៅពេលចាំបាច់។

សូមចងចាំទៅលើចំណុចខាងក្រោម៖

- **ជំនួយការត្រូវការការជួយគាំទ្រ៖** ទាក់ទងទៅមនុស្សដែលអាចទុកចិត្តបានដើម្បីទទួលបានការជួយគាំទ្រ។ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការរក្សាការសម្ងាត់របស់អ្នកឆ្លើយតបនៅពេលដែលស្វែងរកការជួយគាំទ្រណាមួយ។
- **ជំនួយការត្រូវការការសម្រាក៖** ជំនួយការគួរចំណាយពេលវេលាដើម្បីធ្វើសកម្មភាពផ្សេងៗដើម្បីបន្ធូរអារម្មណ៍ឱ្យបានទៀងទាត់ (ឧទាហរណ៍ ការអានសៀវភៅ ការដេរប៉ាក់ ការដើរ ការធ្វើសមាធិ ការមើលភាពយន្ត ការអធិស្ឋាន)។
- **ជំនួយការត្រូវជឿជាក់លើខ្លួនឯង៖** ជំនួយការអាចមានអារម្មណ៍ជឿជាក់លើតួនាទីរបស់ពួកគេ ដោយសិក្សាស្វែងយល់បន្ថែមពីដំណើរការនីតិវិធី CARE តាមរយៈការបណ្តុះបណ្តាល ការអាន និងការសួរសំណួរផ្សេងៗ។ ជំនួយការគួរមានមោទនភាពចំពោះតួនាទីដ៏សំខាន់របស់ខ្លួននៅក្នុងដំណើរការនីតិវិធី CARE។

### ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែមអំពីភាពធន់ និងស្វ័យថែទាំសម្រាប់ជំនួយការ សូមមើល ការបណ្ដុះបណ្ដាល ការអនុវត្តការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេសក្នុងការអនុវត្តផ្ទាល់។

## 8. ធនធានឯកសារនានាសម្រាប់ជំនួយការ

ការពិនិត្យមើល ការបណ្តុះបណ្តាលផ្សេងៗ និងធនធាននានាដែលមាននៅលើ មជ្ឈមណ្ឌលធនធានច្បាប់ CARE អាចជួយដល់ជំនួយការឱ្យយល់កាន់តែច្បាស់អំពីដំណើរការនីតិវិធី CARE និងរបៀបបំពេញការងាររបស់ពួកគេ។

ជំនួយការគួរតែពិចារណាលើការតាមដានពីវឌ្ឍនភាព ហើយគួរធ្វើការកត់ចំណាំទៅលើសំណួរតាមដានណាមួយនៅក្នុងសន្លឹកកិច្ចការជំនួយការស្ម័គ្រចិត្ត។

| ការបណ្តុះបណ្តាល | ការពិពណ៌នា |
|---|---|
| **ទិដ្ឋភាពទូទៅនៃដំណើរការនីតិវិធី CARE សម្រាប់ជំនួយការ (តំណភ្ជាប់)** | ទិដ្ឋភាពទូទៅនៃសារតារ ស្តីពីច្បាប់ CARE តួនាទីនៅក្នុងដំណើរការនីតិវិធី និងការពិពណ៌នាលម្អិតពីដំណើរការនីតិវិធីតុលាការ។ |
| **ទិដ្ឋភាពទូទៅនៃកិច្ចព្រមព្រៀង CARE & គម្រោង CARE សម្រាប់ជំនួយការស្ម័គ្រចិត្ត (តំណភ្ជាប់)** | ផ្តល់នូវទិដ្ឋភាពទូទៅ និងប្រៀបធៀបពីមធ្យោបាយសំខាន់ៗចំនួនបី ឆ្ពោះទៅកាន់សេវាកម្មនៅក្នុងដំណើរការនីតិវិធី CARE ព្រមទាំងការចូលរួមដោយស្ម័គ្រចិត្ត កិច្ចព្រមព្រៀង CARE និងគម្រោង CARE។ ពិភាក្សាស្វែងយល់អំពីធាតុផ្សំនៃកិច្ចព្រមព្រៀង CARE និងគម្រោង CARE ព្រមទាំងសារៈសំខាន់នៃការធ្វើឱ្យកិច្ចព្រមព្រៀង CARE និងគម្រោង CARE សមស្របតាមលក្ខណៈបុគ្គល ដើម្បីបំពេញតាមតម្រូវការរបស់បុគ្គលម្នាក់ៗ។ |
| **លំនៅឋាន សេវាកម្ម និងការជួយគាំទ្រដែលមានតាមរយៈច្បាប់ CARE៖ ការបណ្តុះបណ្តាលសម្រាប់ជំនួយការ (តំណភ្ជាប់)** | ផ្តល់នូវទិដ្ឋភាពទូទៅពីតួនាទីរបស់ជំនួយការស្ម័គ្រចិត្តទាក់ទងនឹងការជួយគាំទ្រ លំនៅឋាន និងសហគមន៍នៅក្នុងច្បាប់ CARE។ ព័ត៌មានលម្អិតអំពីជម្រើសលំនៅឋាន និងការជួយគាំទ្រ ដែលអាចជាផ្នែកមួយនៃដំណើរការនីតិវិធី CARE ព្រមទាំងវិធីសាស្ត្រ ផ្តល់អាទិភាពដល់លំនៅឋាន និងទិដ្ឋភាពទូទៅនៃការបន្តលំនៅឋានសម្រាប់អ្នកចូលរួមនៅក្នុងច្បាប់ CARE និងធាតុផ្សំជាក់លាក់នៃកិច្ចព្រមព្រៀង CARE និងផែនការទាក់ទងនឹងលំនៅឋាន និងការជួយគាំទ្រសហគមន៍។ |

# ច្បាប់ CARE៖ ឯកសារសម្រាប់ជំនួយការស្ម័គ្រចិត្ត

| | |
|---|---|
| **តួនាទីរបស់ជំនួយការនៅក្នុងច្បាប់ CARE (តំណភ្ជាប់)** | ស្វែងយល់ពីតួនាទីរបស់ជំនួយការស្ម័គ្រចិត្តតាមរយៈករណីសិក្សា និងរៀបរាប់ពីការទទួលខុសត្រូវ តម្រូវការ និងធាតុផ្សំរបស់ជំនួយការស្ម័គ្រចិត្ត ច្បាប់ CARE។ |
| **តួនាទីរបស់គ្រួសារនៅក្នុងដំណើរការនីតិវិធី CARE (តំណភ្ជាប់)** | ពិភាក្សាអំពីវិធីសាស្ត្រដែលសមាជិកគ្រួសារអាចចូលរួមបាននៅក្នុងដំណើរការនីតិវិធី CARE ព្រមទាំងក្នុងនាមជាអ្នកដាក់ញត្តិ ជាជំនួយការស្ម័គ្រចិត្ត ឬតាមរយៈការជួយគាំទ្រក្រៅផ្លូវការ។ រៀបចំជំហានសកម្មភាពលម្អិតសម្រាប់គ្រួសារដែលចូលរួមក្នុងដំណើរការនីតិវិធី CARE ដើម្បីជួយគាំទ្រដល់សមាជិកគ្រួសាររបស់ខ្លួន។ |
| **ការសម្រេចចិត្តដោយមានការជួយគាំទ្រសម្រាប់ជំនួយការស្ម័គ្រចិត្ត (តំណភ្ជាប់)** | ផ្តល់និយមន័យនៃការសម្រេចចិត្តដោយមានការជួយគាំទ្រ (SDM) និងគូសបញ្ជាក់ពីគោលគំនិត ព្រមទាំងគោលការណ៍សំខាន់ៗរបស់វា។ រៀបរាប់ពីរបៀបជួយគាំទ្រដល់អ្នកឆ្លើយតបឱ្យធ្វើការសម្រេចចិត្តដោយខ្លួនឯងក្រោមក្របខ័ណ្ឌ SDM។ |
| **ការរក្សាអព្យាក្រឹតភាពក្នុងនាមជាជំនួយការស្ម័គ្រចិត្ត (តំណភ្ជាប់)** | ពិភាក្សាគ្នា ពីទំនាក់ទំនងរវាងជំនួយការ និងអ្នកឆ្លើយតប។ ពិនិត្យមើលលើសារៈសំខាន់នៃការជួយគាំទ្រយ៉ាងពេញលេញដល់ស្វ័យសម្រេចរបស់អ្នកឆ្លើយតប។ សេណារីយ៉ូត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីរបៀបដែលទំនាក់ទំនងផ្សេងគ្នាអាចបង្កបញ្ហាប្រឈមចំពោះដំណើរការនៃការធ្វើការសេចក្តីសម្រេចដោយមានជួយគាំទ្រ។ |
| **ឯកសារណែនាំបម្រុងសម្រាប់ការព្យាបាលជំងឺផ្លូវចិត្ត (តំណភ្ជាប់)** | ពិនិត្យមើលសារតា គោលបំណង និងភ័ស្តុតាងនៃឯកសារណែនាំបម្រុងសម្រាប់ការព្យាបាលជំងឺផ្លូវចិត្ត (PADs)។ ពិភាក្សាពី នៅពេលណា (when) នរណា (who) ដោយរបៀបណា (how) និងអ្វីខ្លះដែលត្រូវធ្វើ (what) ទាក់ទងនឹង PADs នៅក្នុងដំណើរការនីតិវិធី CARE។ |
| **ចង្កោមជំងឺផ្លូវចិត្តដែលទាក់ទងនឹងសង្គម និងការថែទាំផ្អែកលើភស្តុតាង៖ ផ្នែកទី 1 មូលដ្ឋានគ្រឹះជំងឺខ្លាចសង្គម (តំណភ្ជាប់)** | ផ្តល់នូវទិដ្ឋភាពទូទៅនៃជំងឺខ្លាចសង្គម។ ពិភាក្សាអំពីពេលវេលា និងរបៀបនៃការធ្វើរោគវិនិច្ឆ័យជំងឺខ្លាចសង្គម រួមជាមួយនឹងទិដ្ឋភាពទូទៅនៃជំងឺផ្លូវចិត្តពាក់ព័ន្ធ ការធ្វើរោគវិនិច្ឆ័យពាក់ព័ន្ធ និងផលវិបាកនានា។ |
| **ចង្កោមជំងឺផ្លូវចិត្តដែលទាក់ទងនឹងសង្គម និងការថែទាំផ្អែកលើភស្តុតាង៖ ផ្នែកទី 2 ការអនុវត្តផ្អែកលើភស្តុតាងចំពោះជំងឺខ្លាចសង្គម (តំណភ្ជាប់)** | ណែនាំវិធីសាស្ត្រ និងការអនុវត្តន៍ដែលត្រូវបានប្រើដើម្បីព្យាបាលបុគ្គលដែលមានជំងឺខ្លាចសង្គម រួមទាំងវិធីសាស្ត្រផ្តោតលើមនុស្ស ការព្យាបាលសហគមន៍គ្រប់ជ្រុងជ្រោយ និងការផ្តល់ឱសថ។ |

| | |
|---|---|
| **ចង្កោមជំងឺផ្លូវចិត្តដែលទាក់ទងនឹងសង្គម និងការថែទាំផ្អែកលើភស្តុតាង៖ ផ្នែកទី 3 ការជួយគាំទ្រអ្នកដែលមានជំងឺខ្លាចសង្គម ([តំណភ្ជាប់])** | ការណែនាំពីគោលគំនិតដែលត្រូវធ្វើការពិចារណា<br>នៅពេលដែលកំពុងជួយគាំទ្រដល់បុគ្គលដែលមានជំងឺខ្លាចសង្គម។ ផ្តល់យុទ្ធសាស្រ្តដែលមានប្រយោជន៍ ព្រមទាំងរបៀបឆ្លើយតប ចំពោះការវង្វេងស្មារតី និងការបាក់ទឹកចិត្តមិនហ៊ាននិយាយ ដោយប្រើវិធីសាស្រ្តការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេស បង្កើតទំនាក់ទំនង និងជួបពួកគេនៅកន្លែងដែលពួកគេស្ថិតនៅ។ ពិនិត្យមើលទៅលើគំរូនៃការស្តារឡើងវិញ និងការសម្រេចចិត្តដោយមានការជួយគាំទ្រដែលអាចយកមកអនុវត្តចំពោះក្រុមមនុស្សទាំងអស់នេះបាន។ |
| **ការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេសផ្នែកទី 1៖ មូលនិធីសម្រាប់ការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេស ([តំណភ្ជាប់])** | កំណត់ពីការប៉ះទង្គិចផ្លូវចិត្ត និងការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេស។<br>កំណត់កត្តាផ្សេងៗដែលជាមូលហេតុទូទៅនៃការរងរបួស។<br>ផ្តល់នូវទិដ្ឋភាពទូទៅអំពីរបៀបនៃការរងរបួសដែលអាចតម្រូវឱ្យមានការឆ្លើយតប ការប៉ះពាល់ដល់ខួរក្បាល និងអាកប្បកិរិយា។ |
| **ការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេសផ្នែកទី 2៖ គោលដៅ និងគោលការណ៍សម្រាប់ការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេស ([តំណភ្ជាប់])** | គូសបញ្ជាក់អំពីគោលដៅ និងគោលការណ៍នៃការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេស ព្រមទាំងសុវត្ថិភាព កិច្ចសហប្រតិបត្តិការ ភាពជឿជាក់ និងភាពស្មោះត្រង់ ការផ្តល់សិទ្ធិអំណាច ការជួយគាំទ្រពីមិត្តភក្តិបែបវិជ្ជមាន និងក្រៅផ្លូវការ។ លើសពីនេះទៀត សូមពិភាក្សាអំពីបញ្ហាវប្បធម៌ ប្រវត្តិសាស្រ្ត និងយេនឌ័រ។ |
| **ការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេសផ្នែកទី3៖ ការអនុវត្តការថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេសក្នុងនាមជាជំនួយការស្ម័គ្រចិត្ត ([តំណភ្ជាប់])** | ទិដ្ឋភាពទូទៅនៃការប្រើឧបករណ៍ផ្សេងៗ<br>ដើម្បីជួយដល់ជំនួយការក្នុងការកាត់បន្ថយស្ថានភាពតានតឹងនានាដោយប្រើប្រាស់វិធីសាស្រ្តថែទាំការប៉ះទង្គិចផ្លូវចិត្តតាមបទដ្ឋានបច្ចេកទេស<br>ពិភាក្សាអំពីរបៀបលើកកម្ពស់ភាពធន់សម្រាប់អ្នកដែលជួយគាំទ្រដល់អ្នកចូលរួមក្នុងច្បាប់ CARE។ |

| **សេចក្តីសង្ខេប** | **ការពិពណ៌នា** |
|---|---|

# ច្បាប់ CARE៖ ឯកសារសម្រាប់ជំនួយការស្ម័គ្រចិត្ត

| | |
|---|---|
| **តួនាទីរបស់ជំនួយការនៅក្នុងច្បាប់ CARE (តំណភ្ជាប់)** | ផ្តល់ការពន្យល់ទាក់ទងនឹងគោលការណ៍ តួនាទី និងការបណ្តុះបណ្តាលដែលមានសម្រាប់ជំនួយការ។ |
| **លំហូរដំណើរការនីតិវិធី CARE ឆ្ពោះទៅកាន់ការព្យាបាល លំនៅឋាន និងការជួយគាំទ្រ (តំណភ្ជាប់)** | បង្ហាញពីរបៀបនៃវឌ្ឍនភាពរបស់ញត្តិតាមរយៈដំណើរការនីតិវិធី CARE រួមមាន ការចាប់ផ្តើមសំណុំរឿង ការចូលរួម ដំណើរការនីតិវិធីតុលាការ/ការតភ្ជាប់សេវាកម្ម ការផ្តល់សេវាកម្ម និងការវាយតម្លៃបន្តគម្រោងឡើងវិញ ឬបិទបញ្ចប់គម្រោង។ |
| **តួនាទីផ្នែកច្បាប់នៅក្នុងច្បាប់ CARE (តំណភ្ជាប់)** | ព័ត៌មានអំពីតួនាទីផ្លូវច្បាប់ជាក់លាក់ក្នុងដំណើរការនីតិវិធី CARE រួមមាន ទីប្រឹក្សាតំណាងឱ្យអ្នកឆ្លើយតប មន្ត្រីតុលាការ និងតំណាងផ្នែកច្បាប់របស់អ្នកដាក់ញត្តិ។ |
| **សេចក្តីសង្ខេប ច្បាប់ CARE (តំណភ្ជាប់)** | ផ្តល់នូវទិដ្ឋភាពទូទៅនៃច្បាប់ CARE រួមទាំង ការឆ្លើយសំណួរដែលគេសួរញឹកញាប់។ |
| **សន្លឹកព័ត៌មានអំពីលក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបានច្បាប់ CARE (តំណភ្ជាប់)** | ឯកសារពីរទំព័រដែលផ្តល់នូវទិដ្ឋភាពទូទៅនៃលក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន ការធ្វើរោគវិនិច្ឆ័យដែលមានសិទ្ធិទទួលបានច្បាប់ CARE និងព័ត៌មានបន្ថែមផ្សេងទៀត។ មាននៅលើគេហទំព័រក្រុមប្រឹក្សាតុលាការជាភាសាអង់គ្លេស ចិន កូរ៉េ អេស្ប៉ាញ និងវៀតណាម។ |
| **ធនធានច្បាប់ CARE សម្រាប់អ្នកដាក់ញត្តិ (តំណភ្ជាប់)** | ខិត្តប័ណ្ណព័ត៌មានមួយទំព័រសម្រាប់ ធនធានច្បាប់ CARE សម្រាប់ អ្នកដាក់ញត្តិ |